សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
ROYAL UNIVERSITY OF LAW AND ECONOMIC

ថ្នាក់ ៖ បរិញ្ញាបត្រជាន់ខ្ពស់
ផ្នែក ៖ ធុរកិច្ច ( MBM21-2A )
ឯកទេស ៖ គ្រប់គ្រង
មុខវិជ្ជា ៖ គ្រប់គ្រង និងវិភាគគម្រោង
ក្រុម ៖ ទី០៤

# កិច្ចការស្រាវជ្រាវ

## ប្រធានបទ៖

## គម្រោងផ្តល់ធនធានបណ្ណាល័យនៅ អនុវិទ្យាល័យត្រកៀត ដែលស្ថិតនៅ ភូមិត្រកៀត ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ

សាស្ត្រាចារ្យបង្រៀន ៖ បណ្ឌិត **ព្រុំ ទេវី**

**ឆ្នាំសិក្សា ២០២៤ – ២០២៥**

ស្រាវជ្រាវដោយក្រុមនិស្សិត

១.សមាជិក ៖ ជិន ជារស្មី

២.សមាជិក ៖ ឃឹម អ៊ីមី

៣.សមាជិក ៖ ព្រុំ កុសល

៤.សមាជិក ៖ សួស សត្ថាដារីយ៉ា

៥.សមាជិក ៖ អាន់ សុគន្ធារី

៦.សមាជិក ៖ ហ៊ន់ សីហា

៧.សមាជិក ៖ អៀ អេមី

# មាតិកា

**សារតាគម្រោង** ........ III

**ជំពូកទី១៖ ការរៀបចំផែនការគម្រោង** ........ 1

១.១.អំពីគម្រោង ........ 1

១.២.គោលបំណង ........ 1

១.៣. គោលដៅ ........ 1

១.៤.សកម្មភាពនៃគោលដៅ ........ 1

១.៥. ប្រភពថវិកា ........ 3

១.៦.អ្នកទទួលខុសត្រូវ ........ 3

១.៧.សូចនាករ ........ 4

១.៨. មធ្យោបាយផ្ទៀងផ្ទាត់ ........ 6

១.៩. ហានិភ័យ ........ 8

ជំពូកទី២៖ ដំណើរការអនុវត្តគម្រោង និង ការជ្រើសរើសធនធានមនុស្ស ........ 10

២.រចនាសម្ព័ន្ធ និង អង្គការលេខ ........ 10

**២.២. ការប្រើប្រាស់ធនធានគម្រោង** ........ 12

២.៣. ការតាមដានត្រួតពិនិត្យគម្រោង ការវាយតម្លៃគម្រោង និងការតាម ដានបន្ត ........ 12

២.៣.១. ការតាមដានត្រួតពិនិត្យគម្រោង ........ 12

២.៣.២. ការវាយតម្លៃគម្រោង ........ 13

២.៣.៣. ការតាមដានបន្ត ........ 14

២.៤. ការបញ្ចប់គម្រោង និងការផ្ទេរនិរន្តរភាពរបស់គម្រោង ........ 14

២.៤.១. ការបញ្ចប់គម្រោង ........ 14

២.៤.២. ការផ្ទេរនិរន្តភាពរបស់គម្រោង ........ 15

**ជំពូកទី៣ ៖ ការវិភាគ SWOT លើដំណើរការអនុវត្តគម្រោង** ........ 15

៣.១. ចំណុចខ្លាំង ........ 15

៣.២. ចំណុចខ្សោយ ........ 16

៣.៣. ឱកាស ........ 16

៣.៤. ការគំរាមកំហែង ........ 16

**សេចក្ដីសន្និដ្ឋាន** ........ 18

# សាខគាគម្រោង

ក្នុងស្ថានភាពសង្គមសព្វថ្ងៃ ប្រទេសកម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលនៃការរីកចម្រើនយ៉ាងច្រើនទាំងក្នុងវិស័យសេដ្ឋកិច្ច និងវិស័យអប់រំ។ ទោះជាយ៉ាងណា តំបន់ជនបទមួយចំនួន ដូចជាភូមិត្រកៀត ខេត្តតាកែវ នៅតែប្រឈមមុខនឹងបញ្ហាផ្សេងៗ ជាពិសេសការខ្វះខាតធនធាន និងគ្រឿងបរិក្ខារសម្រាប់បណ្ណាល័យដែលមានសារៈសំខាន់ក្នុងការជួយជាជំនួយដល់លទ្ធផលសិក្សាអោយសម្ភារៈជំនួយស្មារតីគ្រប់គ្រាន់ និងជំរុញឱ្យសិស្សមានទម្លាប់ល្អក្នុងការអានសៀវភៅ។

ដោយយល់ឃើញពីបញ្ហានេះ ក្រុមនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី២១ ជំហានទី២ (MBM21-2A) នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានបង្កើតគម្រោងសប្បុរសធម៌មួយដែលមានចំណងជើងថា"**គម្រោងផ្តល់ធនធានបណ្ណាល័យនៅអនុវិទ្យាល័យត្រកៀត ស្រុកបាទី ខេត្តតាកែវ**"។ គោលបំណងសំខាន់របស់គម្រោងនេះ គឺផ្តល់ធនធាន និងសម្ភារៈមួយចំនួនសម្រាប់ប្រើប្រាសើក្នុងបណ្ណាល័យ ដល់សិស្សនៅសាលាអនុវិទ្យាល័យដែលនៅក្នុងតំបន់ កំពុងមានការខ្វះខាតពិតប្រាកដ។

គម្រោងនេះក៏ជាឱកាសឱ្យនិស្សិតអនុវត្តន៍ចំណេះដឹងជាក់ស្តែង ដូចជា ការរៀបចំផែនការ ការបែងចែកភារកិច្ច ការគ្រប់គ្រងថវិកា ការរៀបចំរបាយការណ៍ ការស្វែងរកឧបត្ថម្ភ និងជាពិសេសការចូលរួមស្ម័គ្រចិត្តជាមួយសហគមន៍។ ការចូលរួមទាំងនេះជួយពង្រឹងទំនាក់ទំនងសហគមន៍ និងជំរុញឱ្យការអប់រំតាមតំបន់ជនបទមានគុណភាពកាន់តែប្រសើរ។

ដើម្បីអនុវត្តបានប្រសើរឡើង គម្រោងត្រូវបានបែងចែកជាវគ្គសំខាន់ៗ ៣ គឺ៖

១.ការរៀបចំផែនការកម្មវិធី និងចុះសិក្សាព័ត៌មានក្នុងតំបន់គោលដៅ។

២.ការដឹកជញ្ជូន និងចែកចាយធនធានបណ្ណាល័យ។

៣.ការវាយតម្លៃលទ្ធផល និងបង្ហោះរបាយការណ៍សរុប។

គម្រោងនេះ បង្កើតដើម្បីជាការបង្ហាញពីទឹកចិត្តសប្បុរស និងការយកចិត្តទុកដាក់របស់និស្សិត ក្នុងការចូលរួមជំរុញដល់ការអភិវឌ្ឍសហគមន៍តាមវិធីសាមញ្ញ ប៉ុន្តែមានតម្លៃខ្ពង់ខ្ពស់ពោរពេញដោយគុណធម៌ និងទឹកចិត្ត។

# ជំពូកទី១៖ ការរៀបចំផែនការគម្រោង

## ១.១.អំពីគម្រោង

គម្រោងនេះមានឈ្មោះថា កម្មវិធីផ្តល់ធនធានបណ្ណាល័យសម្រាប់អនុវិទ្យាល័យ ត្រកៀត ដែលស្ថិតនៅ ភូមិត្រកៀត ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ។

## ១.២.គោលបំណង

ដើម្បីបង្កើននូវមធ្យោបាយក្នុងការសិក្សាស្រាវជ្រាវ និងបង្កើតទម្លាប់ក្នុងការអានសៀវភៅរបស់សិស្សានុសិស្សនៅអនុវិទ្យាល័យ ត្រកៀត តាមរយៈការចូលរួមចំណែកឧបត្ថម្ភជាសម្ភារៈបណ្ណាល័យ។

## ១.៣. គោលដៅ

គម្រោងនេះមានគោលដៅសិក្សាលម្អិតចំនួន ៣ ដូចខាងក្រោម៖

**<u>គោលដៅទី១</u>៖** បង្កើតក្រុមការងារ ពិភាក្សាពីតម្រូវការធនធានបណ្ណាល័យ សកម្មភាពគម្រោង ផែនការហិរញ្ញវត្ថុ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាន គណៈគ្រប់គ្រងសាលា ដើម្បីសិក្សាអំពីស្ថានភាព និង កំណត់តម្រូវការជាក់លាក់ យ៉ាងយឺតបំផុតត្រឹមសប្តាហ៍ទី៣ ខែ កញ្ញា ឆ្នាំ២០២៥។

**<u>គោលដៅទី២</u>៖** ដំណើរដល់ទីតាំង ដើម្បីរៀបចំប្រគល់ធនធានបណ្ណាល័យ ដល់គណៈគ្រប់គ្រងសាលានិងចូលរួមថតរូបទុកជាអនុស្សាវរីយ៍ជាមួយលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សយ៉ាង យឺតបំផុតត្រឹមសប្តាហ៍ទី៤ ខែ កញ្ញា ឆ្នាំ២០២៥។

**<u>គោលដៅទី៣</u>៖** បូកសរុបលទ្ធផលការងារ និងចំណាយសម្រាប់ការអនុវត្តគម្រោងទាំងមូល និងសរសេរជារបាយការណ៍ សម្រាប់ប្រគល់ជូនភាគីដែលពាក់ព័ន្ធយ៉ាងយូរបំផុតត្រឹមសប្តាហ៍ទី៣ ខែតុលា ឆ្នាំ ២០២៥។

## ១.៤.សកម្មភាពនៃគោលដៅ

ដើម្បីសម្រេចបាននូវគោលដៅនីមួយៗនៃគម្រោងនេះ មានសកម្មភាពសំខាន់ៗសម្រាប់ចូលរួមសម្រេចនូវគោលដៅទាំងបីខាងលើ មានដូចខាងក្រោម៖

**គោលដៅទី១៖** បង្កើតក្រុមការងារ ពិភាក្សាពីតម្រូវការធនធានបណ្ណាល័យ សកម្មភាពគម្រោង ផែនការហិរញ្ញវត្ថុ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាន គណៈគ្រប់គ្រងសាលា ដើម្បីសិក្សាអំពីស្ថានភាព និង កំណត់តម្រូវការជាក់លាក់ យ៉ាងយឺតបំផុតត្រឹមសប្តាហ៍ទី៣ ខែ កញ្ញា ឆ្នាំ២០២៥។

**សកម្មភាពទី១.១៖** បែកចែកតួនាទីនៃសមាជិកគម្រោងទៅលើការធ្វើផែនការហិរញ្ញវត្ថុ និងទាក់ទងអាជ្ញាធរមូលដ្ឋានព្រមទាំងនាយកសាលារយៈពេលពីរថ្ងៃក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៥។

**សកម្មភាពទី១.២៖** ជួបពិភាក្សាជាមួយគណៈគ្រប់គ្រងសាលាដើម្បីដឹងពីតម្រូវការធនធានបណ្ណាល័យជាក់ស្តែង រយៈពេលពីរថ្ងៃ ក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៥។

**សកម្មភាពទី១.៣៖** ការរៃអង្គាសប្រមូលថវិកាដើម្បីយកមកបែងចែក តាមកញ្ចប់ចំណាយនីមួយៗ និងធ្វើរបាយការណ៍បូកសរុបចំណូលចំណាយ ដោយយ៉ាងយូរបំផុតត្រឹមសប្តាហ៍ទី៣ នៃខែកញ្ញា ឆ្នាំ២០២៥។

**គោលដៅទី២៖** ដំណើរដល់ទីតាំង ដើម្បីរៀបចំប្រគល់ធនធានបណ្ណាល័យ ដល់គណៈគ្រប់គ្រងសាលានិងចូលរួមថតរូបទុកជាអនុស្សាវរីយ៍ជាមួយលោកគ្រូ អ្នកគ្រូនិងសិស្សានុសិស្សយ៉ាងយឺតបំផុតត្រឹមសប្តាហ៍ទី៤ ខែកញ្ញា ឆ្នាំ២០២៥។

**សកម្មភាពទី២.១៖** សិក្សាពីតម្លៃថ្លៃដើមនៃធនធានបណ្ណាល័យតាមការកំណត់ជាមួយបណ្តាអ្នកផ្គត់ផ្គង់ដោយមិនលើសពីសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៥។

**សកម្មភាពទី២.២៖** ដឹកជញ្ជូនសម្ភារៈទៅកាន់ទីតាំងនិងរៀបចំតម្លើង ក្នុងសប្តាហ៍ទី៤ ខែកញ្ញា ឆ្នាំ ២០២៥។សំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស រួចធ្វើការប្រគល់ធនធានបណ្ណាល័យជូនដល់គណៈគ្រប់គ្រងសាលា ក្នុងសប្តាហ៍ទី៤ ខែកញ្ញា ឆ្នាំ២០២៥។

**សកម្មភាទី២.៣៖** មានការលេងល្បែងកំសាន្តជាមួយសិស្សានុសិស្ស ការថតរូបទុកជាអនុស្សាវរីយ៍ និងថ្លែងអំណរគុណដល់សប្បុរសជន ក្នុងសប្តាហ៍ទី៤ ខែ កញ្ញា ឆ្នាំ២០២៥

**គោលដៅទី៣៖** បូកសរុបលទ្ធផលការងារ និងចំណាយសម្រាប់ការអនុវត្តគម្រោងទាំងមូល និងសរសេរជារបាយការណ៍ សម្រាប់ប្រគល់ជូនភាគីដែលពាក់ព័ន្ធយ៉ាងយូរបំផុតត្រឹមសប្តាហ៍ទី៣ ខែតុលា ឆ្នាំ ២០២៥។

**សកម្មភាពទី៣.១៖** ក្រុមការងារបានធ្វើការបូកសរុបថវិកា ដែលបានចំណាយសម្រាប់គម្រោងទាំងមូល នៅត្រឹមសប្តាហ៍ទី២ ខែ តុលា ឆ្នាំ ២០២៥។

**សកម្មភាពទី៣.២៖** វិភាគទិន្នន័យ និងចងក្រងមតិយោបល់ដោយក្រុមការងារធ្វើការវិភាគផ្នែកបច្ចេកទេស និងផ្នែកសង្គមសាស្ត្រលើទិន្នន័យស្របតាមគោលបំណងគម្រោង ដើម្បីចេញនូវសេចក្តីសន្និដ្ឋាន។

**សកម្មភាទី៣.៣៖** ក្រុមការងារសរសេរបញ្ចប់របាយការណ៍ជូនសាធារណជនឬអ្នកដែលបានចូលរួមដោយខ្លឹមសារស្តីអំពីការស្រាវជ្រាវ ការអនុវត្ត និងលទ្ធផលនានានៃគម្រោង ដែលមានការរួមបញ្ចូលទិន្នន័យវាយតម្លៃ ការប្រៀបធៀប និងសំណួរស្រាវជ្រាវ។ការបញ្ចប់នៃសកម្មភាពនេះនឹងប្រព្រឹត្តទៅនៅសប្តាហ៍ទី៣ ខែ តុលា ឆ្នាំ ២០២៥។

**១.៥. ប្រភពថវិកា**

ការអនុវត្តគម្រោងនេះគឺត្រូវចំណាយទឹកប្រាក់ប្រមាណ **១១០០ដុល្លារអាមេរិក** ដែលបានមកពីប្រភពផ្សេងៗមានដូចជា៖

- ថវិកាផ្ទាល់ខ្លួនរបស់សមាជិកក្រុមចំនួន **១៤០ ដុល្លារអាមេរិក**(សម្រាប់គោលដៅទី១)
- ការរៃអង្គាសពីបណ្ដាសិស្សនិស្សិត និងលោកគ្រូ អ្នកគ្រូ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចចំនួន **៤០០ដុល្លារអាមេរិក** (សម្រាប់គោលដៅទី២)
- ការរៃអង្គាសពីសមាជិកមិត្តរួមការងារ **១០០ដុល្លារអាមេរិក** (សម្រាប់គោលដៅទី២)
- និងការរៃអង្គាសពីសារធារណជនតាមបណ្ដាញសង្គមចំនួន **៤៦០ដុល្លារ**(សម្រាប់គោលដៅទី៣)

**១.៦.អ្នកទទួលខុសត្រូវ**

**គោលដៅទី១៖** បង្កើតក្រុមការងារ ពិភាក្សាពីតម្រូវការធនធានបណ្ណាល័យ សកម្មភាពគម្រោង ផែនការហិរញ្ញវត្ថុ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាន គណៈគ្រប់គ្រងសាលា ដើម្បីសិក្សាអំពីស្ថានភាព និង កំណត់តម្រូវការជាក់លាក់ យ៉ាងយឺតបំផុតត្រឹមសប្ដាហ៍ទី៣ ខែ កញ្ញា ឆ្នាំ២០២៥។

**សកម្មភាពទី១.១៖** បែកចែកតួនាទីនៃសមាជិកគម្រោងទៅលើការធ្វើផែនការហិរញ្ញវត្ថុ និងទាក់ទងអាជ្ញាធរមូលដ្ឋានព្រមទាំងនាយកសាលារយៈពេលមួយថ្ងៃក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៥។

អ្នកទទួលខុសត្រូវសម្រាប់សកម្មភាពទី១.១៖ **កញ្ញា ជិន ជារស្មី**។

**សកម្មភាពទី១.២៖** ចុះជួបពិភាក្សាជាមួយគណៈគ្រប់គ្រងសាលាដើម្បីដឹងពីតម្រូវការធនធានបណ្ណាល័យជាក់ស្ដែង រយៈពេលពីរថ្ងៃ ក្នុងសប្ដាហ៏ទី៣ ខែកញ្ញា ឆ្នាំ២០២៥។

អ្នកទទួលខុសត្រូវសម្រាប់សកម្មភាពទី១.២៖ **លោក ព្រុំ កុសល**។

**សកម្មភាពទី១.៣៖** ការរៃអង្គាសប្រមូលថវិកាដើម្បីយកមកបែងចែក តាមកញ្ចប់ចំណាយនីមួយៗ និងធ្វើរបាយការណ៏បូកសរុបចំណូលចំណាយ ដោយយ៉ាងយូរបំផុតត្រឹមសប្ដាហ៏ទី៣ នៃខែកញ្ញា ឆ្នាំ២០២៥។

អ្នកទទួលខុសត្រូវសម្រាប់សកម្មភាពទី១.៣៖ **អ្នកស្រី ឃឹម អីមី**។

**គោលដៅទី២៖** ដំណើរដល់ទីតាំង ដើម្បីរៀបចំប្រគល់ធនធានបណ្ណាល័យ ដល់គណៈគ្រប់គ្រងសាលានិងចូលរួមថតរូបទុកជាអនុស្សាវរីយ៍ជាមួយលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សយ៉ាង យឺតបំផុតត្រឹមសប្ដាហ៍ទី៤ ខែ កញ្ញា ឆ្នាំ២០២៥។

**សកម្មភាពទី២.១៖** សិក្សាពីតម្លៃថ្លៃដើមនៃធនធានបណ្ណាល័យតាមការកំណត់ជាមួយបណ្តាអ្នកផ្គត់ផ្គង់ដោយមិនលើសពីសប្តាហ៍ទី៣ ខែ កញ្ញា ឆ្នាំ២០២៥។

អ្នកទទួលខុសត្រូវសម្រាប់គោលដៅទី២.១៖ **កញ្ញា សួស សត្ថាដារីយ៉ា**។

**សកម្មភាពទី២.២៖** ដឹកជញ្ជូនសម្ភារៈទៅកាន់ទីតាំងនិងរៀបចំតម្លើង ក្នុងសប្តាហ៍ទី៤ ខែកញ្ញា ឆ្នាំ ២០២៥។សំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស រួចធ្វើការប្រគល់ធនធានបណ្ណាល័យជូនដល់គណៈគ្រប់គ្រងសាលា ក្នុងសប្តាហ៍ទី៤ ខែ កញ្ញា ឆ្នាំ២០២៥។

អ្នកទទួលខុសត្រូវសម្រាប់សកម្មភាពទី២.២៖ លោក **ហ៊ន់ សីហា**។

**សកម្មភាពទី២.៣៖** មានការលេងល្បែងកំសាន្តជាមួយសិស្សានុសិស្ស ការថតរូបទុកជាអនុស្សាវរីយ៍ និងថ្លែងអំណរគុណដល់សប្បុរសជន ក្នុងសប្តាហ៍ទី៤ ខែ កញ្ញា ឆ្នាំ២០២៥។

អ្នកទទួលខុសត្រូវសម្រាប់សកម្មភាពទី២.៣៖ **កញ្ញា អៀ អេមី**។

**គោលដៅទី៣៖** បូកសរុបលទ្ធផលការងារ និង ចំណាយសម្រាប់ការអនុវត្តគម្រោងទាំងមូល និងសរសេរជារបាយការណ៍ សម្រាប់ប្រគល់ជូនភាគីដែលពាក់ព័ន្ធយ៉ាងយូរបំផុតត្រឹមសប្តាហ៍ទី៣ខែតុលា ឆ្នាំ ២០២៥។

**សកម្មភាពទី៣.១៖** ក្រុមការងារបានធ្វើការបូកសរុបថវិកា ដែលបានចំណាយសម្រាប់គម្រោងទាំងមូលនៅត្រឹមសប្តាហ៍ទី២ ខែ តុលា ឆ្នាំ ២០២៥។

អ្នកទទួលខុសត្រូវសម្រាប់គម្រោងសកម្មភាពទី៣.១៖ **អ្នកស្រី អាន សុគន្ធារី**។

**សកម្មភាពទី៣.២៖** ក្រុមការងារបូកសរុបនូវលទ្ធផលនានានៃគម្រោងនៅនៅត្រឹមសប្តាហ៍ទី២ ខែ តុលា ឆ្នាំ ២០២៥។

អ្នកទទួលខុសត្រូវសកម្មភាពទី៣.២៖ **អ្នកស្រី អាន សុគន្ធារី**។

**សកម្មភាពទី៣.៣៖** ក្រុមការងារសរសេរបញ្ចប់របាយការណ៍ជូនសាធារណជនឬអ្នកដែលបានចូលរួមដោយខ្លឹមសារស្តីអំពីការស្រាវជ្រាវ ការអនុវត្ត និងលទ្ធផលនានានៃគម្រោង ដែលមានការរួមបញ្ចូលទិន្នន័យវាយតម្លៃ ការប្រៀបធៀប និងសំណួរស្រាវជ្រាវ។ការបញ្ចប់នៃសកម្មភាពនេះនឹងប្រព្រឹត្តទៅនៅសប្តាហ៍ទី៣ ខែ តុលា ឆ្នាំ ២០២៥។

អ្នកទទួលខុសត្រូវសកម្មភាពទី៣.៣៖ **កញ្ញា ជិន ជារស្មី**។

### ១.៧.សូចនាករ

សូចនាករសម្រាប់វាស់វែង នៅក្នុងគម្រោងនេះ រួមមាន៖

**គោលដៅទី ១៖** បង្កើតក្រុមការងារ ពិភាក្សាពីតម្រូវការធនធានបណ្ណាល័យ សកម្មភាពគម្រោង ផែនការហិរញ្ញវត្ថុ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាន គណៈគ្រប់គ្រងសាលា ដើម្បីសិក្សាអំពី

ស្ថានភាពជាក់ស្តែងក៏ដូចជា កំណត់តម្រូវការជាក់លាក់ យ៉ាងយឺតបំផុតត្រឹមសប្តាហ៍ទី៣ ខែ កញ្ញា ឆ្នាំ២០២៥។បង្កើតក្រុមការងារ ពិភាក្សាពីតម្រូវការធនធានបណ្ណាល័យ សកម្មភាពគម្រោង ផែនការហិរញ្ញវត្ថុ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាន គណៈគ្រប់គ្រងសាលា ដើម្បីសិក្សាអំពីស្ថានភាព និង កំណត់តម្រូវការជាក់លាក់ យ៉ាងយឺតបំផុតត្រឹមសប្តាហ៍ទី៣ ខែ កញ្ញា ឆ្នាំ២០២៥។

**សកម្មភាពទី១.១៖** បែកចែកតួនាទីនៃសមាជិកគម្រោងទៅលើការធ្វើផែនការហិរញ្ញវត្ថុ និងទាក់ទងអាជ្ញាធរមូលដ្ឋានព្រមទាំងនាយកសាលារយៈពេលមួយថ្ងៃក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៥។

***សូចនាករទី១.១.១៖*** សម្រេចឲ្យបានជាស្ថាពរ នូវការបង្កើតក្រុមការងារទទួលខុសត្រូវច្បាស់លាស់តាមភារកិច្ច តួនាទី ទំនួលខុសត្រូវ សម្រាប់សមាជិកម្នាក់ៗត្រឹមសប្តាហ៍ទី ៣ ខែ កញ្ញា ឆ្នាំ ២០២៥។

**សកម្មភាពទី១.២៖** ជួបពិភាក្សាជាមួយគណៈគ្រប់គ្រងសាលាដើម្បីដឹងពីតម្រូវការធនធានបណ្ណាល័យជាក់ស្តែង រយៈពេលពីរថ្ងៃ ក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៥។

***សូចនាករទី១.២.១៖*** សម្រេចឲ្យបានជាស្ថាពរនូវ ចុះដល់ទីតាំងដើម្បីជួបពិភាក្សាជាមួយគណៈគ្រប់គ្រងសាលាដើម្បីធ្វើការកំណត់តម្រូវការធនធានបណ្ណាល័យសម្រាប់ប្រគល់ជូនសិស្សានុសិស្សត្រឹមសប្តាហ៍ទី ៣ ខែកញ្ញា ឆ្នាំ២០២៥។

**សកម្មភាពទី១.៣៖** ការរៃអង្គាសប្រមូលថវិកាដើម្បីយកមកបែងចែក តាមកញ្ចប់ចំណាយនីមួយៗ និងធ្វើរបាយការណ៍បូកសរុបចំណូលចំណាយ ដោយយ៉ាងយូរបំផុតត្រឹមសប្តាហ៍ទី៣ នៃខែកញ្ញា ឆ្នាំ ២០២៥។

***សូចនាករទី១.៣.១៖*** សម្រេចឲ្យបានជាស្ថាពរនូវការប្រមូលថវិកា កំណត់សកម្មភាពសម្រាប់ថ្ងៃកម្មវិធី និងរៀបចំកញ្ចប់អំណោយ ត្រឹមសប្តាហ៍ទី ៣ នៃ កញ្ញា ឆ្នាំ ២០២៥។

**គោលដៅទី២៖** ដំណើរដល់ទីតាំង ដើម្បីរៀបចំប្រគល់ធនធានបណ្ណាល័យ ដល់គណៈគ្រប់គ្រងសាលានិងចូលរួមថតរូបទុកជាអនុស្សាវរីយ៍ជាមួយលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សយ៉ាង យឺតបំផុតត្រឹមសប្តាហ៍ទី៤ ខែ កញ្ញា ឆ្នាំ២០២៥។

**សកម្មភាពទី២.១៖** សិក្សាពីតម្លៃថ្លៃដើមនៃធនធានបណ្ណាល័យតាមការកំណត់រួចរាល់ជាមួយបណ្តាអ្នកផ្គត់ផ្គង់ដោយមិនលើសពីសប្តាហ៍ទី៣ ខែ កញ្ញា ឆ្នាំ២០២៥។

***សូចនាករទី ២.១.១៖*** សម្រេចជាស្ថាពរនូវ ការសិក្សាអំពីតម្លៃថ្លៃដើមនៃធនធានបណ្ណាល័យពីអ្នកផ្គត់ផ្គង់ត្រឹមសប្តាហ៍ទី ៣ ខែ កញ្ញា ឆ្នាំ ២០២៥។

**សកម្មភាពទី២.២៖** ដឹកជញ្ជូនសម្ភារៈទៅកាន់ទីតាំងនិងរៀបចំតម្លើង ក្នុងសប្តាហ៍ទី៤ ខែកញ្ញា ឆ្នាំ ២០២៥។សំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស រួចធ្វើការប្រគល់ធនធានបណ្ណាល័យជូនដល់គណៈគ្រប់គ្រងសាលា រយៈពេលកន្លះថ្ងៃក្នុងសប្តាហ៍ទី៤ ខែ កញ្ញា ឆ្នាំ២០២៥។

***សូចនាករទី ២.២.១៖*** សម្រេចជាស្ថាពរនូវ ការដឹកជញ្ជូនកញ្ចប់អំណោយ និងប្រគល់ទៅកាន់ទីតាំងកម្មវិធីទាន់ពេលវេលាត្រឹមសប្តាហ៍ទី ៤ ខែ កញ្ញា ឆ្នាំ ២០២៥។

**សកម្មភាពទី២.៣៖** មានការលេងល្បែងកំសាន្តជាមួយសិស្សានុសិស្ស ការថតរូបទុកជាអនុស្សាវរីយ៍ និងថ្លែងអំណរគុណដល់សប្បុរសជន ក្នុងសប្តាហ៍ទី៤ ខែ កញ្ញា ឆ្នាំ២០២៥

***សូចនាករទី ២.៣.១៖*** ក្រុមការងាររៀបចំ និងផ្តិតយករូបភាពជាមួយនឹងវីដេអូនៃសកម្មភាពគម្រោងក្នុងសប្តាហ៍ទី ៤ ខែ កញ្ញា ឆ្នាំ ២០២៥។

**គោលដៅទី៣៖** បូកសរុបលទ្ធផលការងារ និងចំណាយសម្រាប់ការអនុវត្តគម្រោងទាំងមូល និងសរសេរជារបាយការណ៍ សម្រាប់ប្រគល់ជូនភាគីដែលពាក់ព័ន្ធយ៉ាងយូរបំផុតត្រឹមសប្តាហ៍ទី៣ ខែ តុលា ឆ្នាំ ២០២៥។

**សកម្មភាពទី៣.១៖** ក្រុមការងារបានធ្វើការបូកសរុបថវិកា ដែលបានចំណាយសម្រាប់គម្រោងទាំងមូលនៅត្រឹមសប្តាហ៍ទី២ ខែ តុលា ឆ្នាំ ២០២៥។

***សូចនាករទី ៣.១.១៖*** សម្រេចជាស្ថាពរ នូវបញ្ជីចំណាយសម្រាប់គម្រោងទាំងមូលនៅត្រឹមសប្តាហ៍ទី ២ ខែ តុលា ឆ្នាំ ២០២៥។

**សកម្មភាពទី៣.២៖** ក្រុមការងារបូកសរុបនូវលទ្ធផលនានានៃគម្រោងនៅនៅត្រឹមសប្តាហ៍ទី២ ខែ តុលា ឆ្នាំ ២០២៥។

***សូចនាករទី ៣.២.១៖*** សម្រេចឲ្យបានជាស្ថាពរនូវ បញ្ជីលទ្ធផលនៃគម្រោងត្រឹមសប្តាហ៍ទី២ ខែ តុលា ឆ្នាំ ២០២៥។

**សកម្មភាពទី៣.៣៖** ក្រុមការងារសរសេរបញ្ចប់របាយការណ៍ជូនសាធារណជនឬអ្នកដែលបានចូលរួមដោយខ្លឹមសារស្តីអំពីការស្រាវជ្រាវ ការអនុវត្ត និងលទ្ធផលនានានៃគម្រោង ដែលមានការរួមបញ្ចូលទិន្នន័យវាយតម្លៃ ការប្រៀបធៀប និងសំណួរស្រាវជ្រាវ។ការបញ្ចប់នៃសកម្មភាពនេះនឹងប្រព្រឹត្តទៅនៅសប្តាហ៍ទី៣ ខែ តុលា ឆ្នាំ ២០២៥។

***សូចនាករទី ៣.៣.១៖*** សម្រេចបានជាស្ថាពរនូវ របាយការណ៍ចុងក្រោយនៃគម្រោង និង ប្រគល់ជូនអ្នកដែលពាក់ព័ន្ធ ត្រឹមសប្តាហ៍ទី ៣ ខែ តុលា ឆ្នាំ ២០២៥។

### ១.៨. មធ្យោបាយផ្ទៀងផ្ទាត់

មធ្យោបាយផ្ទៀងផ្ទាត់នៅក្នុងគម្រោងនេះរួមមាន៖

**គោលដៅទី ១៖** បង្កើតក្រុមការងារ ពិភាក្សាពីតម្រូវការធនធានបណ្ណាល័យ សកម្មភាពគម្រោង ផែនការហិរញ្ញវត្ថុ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាន គណៈគ្រប់គ្រងសាលា ដើម្បីសិក្សាអំពីស្ថានភាព និង កំណត់តម្រូវការជាក់លាក់ យ៉ាងយឺតបំផុតត្រឹមសប្តាហ៍ទី៣ ខែ កញ្ញា ឆ្នាំ២០២៥។

**សកម្មភាពទី១.១៖** បែកចែកតួនាទីនៃសមាជិកគម្រោងទៅលើការធ្វើផែនការហិរញ្ញវត្ថុ និងទាក់ទងអាជ្ញាធរមូលដ្ឋានព្រមទាំងនាយកសាលារយៈពេលមួយថ្ងៃក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៥។

***មធ្យោបាយផ្ទៀងផ្ទាត់ទី១.១.១.៖*** បញ្ជីឈ្មោះក្រុមការងារ។

**សកម្មភាពទី១.២៖** ជួបពិភាក្សាជាមួយគណៈគ្រប់គ្រងសាលាដើម្បីដឹងពីតម្រូវការធនធានបណ្ណាល័យជាក់ស្តែង រយៈពេលពីរថ្ងៃ ក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៥។

***មធ្យោបាយផ្ទៀងផ្ទាត់ទី១.២.១៖*** បញ្ជីតម្រូវការធនធានបណ្ណាល័យ

**សកម្មភាពទី១.៣៖** ធ្វើការរៃអង្គាសប្រមូលថវិកាដើម្បីយកមកបែងចែក តាមកញ្ចប់ចំណាយនីមួយៗ និងធ្វើរបាយការណ៍បូកសរុបចំណូលចំណាយ ដោយយ៉ាងយូរបំផុតត្រឹមសប្តាហ៏ទី៣ នៃខែកញ្ញា ឆ្នាំ ២០២៥។

***មធ្យោបាយផ្ទៀងផ្ទាត់ទី១.៣.១៖*** បញ្ជីឈ្មោះអ្នកបរិច្ចាក បញ្ជីឈ្មោះសម្ភារៈសម្រាប់ប្រគល់នៅថ្ងៃកម្មវិធី។

**គោលដៅទី២៖** ដំណើរដល់ទីតាំង ដើម្បីរៀបចំប្រគល់ធនធានបណ្ណាល័យ ដល់គណៈគ្រប់គ្រងសាលានិងចូលរួមថតរូបទុកជាអនុស្សាវរូយ៍ជាមួយលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សយ៉ាង យឺតបំផុតត្រឹមសប្តាហ៍ទី៤ ខែ កញ្ញា ឆ្នាំ២០២៥។

**សកម្មភាពទី២.១៖** សិក្សាពីតម្លៃថ្លៃដើមនៃធនធានបណ្ណាល័យតាមការកំណត់ជាមួយបណ្តាអ្នកផ្គត់ផ្គង់ដោយមិនលើសពីសប្តាហ៏ទី៣ ខែ កញ្ញា ឆ្នាំ២០២៥។

***មធ្យោបាយផ្ទៀងផ្ទាត់ទី២.១.១៖*** បញ្ជីរាយតម្លៃនៃសម្ភារៈនីមួយៗពីអ្នកផ្គត់ផ្គង់។

**សកម្មភាពទី២.២៖** ដឹកជញ្ជូនសម្ភារៈទៅកាន់ទីតាំងនិងរៀបចំតម្លើង ក្នុងសប្តាហ៏ទី៤ ខែកញ្ញា ឆ្នាំ ២០២៥។សំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស រួចធ្វើការប្រគល់ធនធានបណ្ណាល័យជូនដល់គណៈគ្រប់គ្រងសាលា ក្នុងសប្តាហ៏ទី៤ ខែ កញ្ញា ឆ្នាំ២០២៥។

***មធ្យោបាយផ្ទៀងផ្ទាត់ទី២.២.១៖*** ធនធានអំណោយ និងបញ្ជីរបៀបវារៈ។

**សកម្មភាពទី២.៣៖** មានការលេងល្បែងកំសាន្តជាមួយសិស្សានុសិស្ស ការថតរូបទុកជាអនុស្សាវរីយ៍ និងថ្លែងអំណរគុណដល់សប្បុរសជន ក្នុងសប្តាហ៏ទី៤ ខែ កញ្ញា ឆ្នាំ២០២៥។

***មធ្យោបាយផ្ទៀងផ្ទាត់ទី២.៣.១៖*** កម្រងរូបភាព និងវិដេអូនៃសកម្មភាពគម្រោង។

**គោលដៅទី៣៖បូកសរុបលទ្ធផលការងារ និង ចំណាយសម្រាប់ការអនុវត្តគម្រោងទាំងមូល និងសរសេរជារបាយការណ៍ សម្រាប់ប្រគល់ជូនភាគីដែលពាក់ព័ន្ធយ៉ាងយូរបំផុតត្រឹមសប្តាហ៍ទី៣ ខែ តុលា ឆ្នាំ ២០២៥។**

**សកម្មភាពទី៣.១៖** ក្រុមការងារបានធ្វើការបូកសរុបថវិកា ដែលបានចំណាយសម្រាប់គម្រោងទាំងមូល។នៅត្រឹមសប្តាហ៍ទី២ ខែ តុលា ឆ្នាំ ២០២៥។

***មធ្យោបាយផ្ទៀងផ្ទាត់ទី៣.១.១៖*** បញ្ជីរាល់ការចំណាយ និង វិក័យប័ត្រទូទាត់ប្រាក់។

**សកម្មភាពទី៣.២៖** ក្រុមការងារបូកសរុបនូវលទ្ធផលនានានៃគម្រោងនៅនៅត្រឹមសប្តាហ៍ទី២ ខែ តុលា ឆ្នាំ ២០២៥។

***មធ្យោបាយផ្ទៀងផ្ទាត់ទី៣.២.១៖*** កម្រងរូបថត និង វិដេអូអនុស្សាវរីយ៍នៃសកម្មភាពគម្រោង។

**សកម្មភាពទី៣.៣៖** ក្រុមការងារសរសេរបញ្ចប់របាយការណ៍ជូនសាធារណជនឬអ្នកដែលបានចូលរួមដោយខ្លឹមសារស្តីអំពីការស្រាវជ្រាវ ការអនុវត្ត និងលទ្ធផលនានានៃគម្រោង ដែលមានការរួមបញ្ចូលទិន្នន័យវាយតម្លៃ ការប្រៀបធៀប និងសំណួរស្រាវជ្រាវ។ការបញ្ចប់នៃសកម្មភាពនេះនឹងប្រព្រឹត្តទៅនៅសប្តាហ៍ទី៣ ខែ តុលា ឆ្នាំ ២០២៥។

***មធ្យោបាយផ្ទៀងផ្ទាត់ទី៣.៣.១៖*** របាយការណ៍ផ្លូវការចុងក្រោយរបស់គម្រោង និង លិខិតបញ្ជាក់ទទួលនូវរបាយការណ៍ពីអ្នកដែលពាក់ព័ន្ធ។

### ១.៩. ហានិភ័យ

**ហានិភ័យ នៅក្នុងគម្រោងនេះរួមមាន៖**

**គោលដៅទី ១៖** បង្កើតក្រុមការងារ ពិភាក្សាពីតម្រូវការធនធានបណ្ណាល័យ សកម្មភាពគម្រោង ផែនការហិរញ្ញវត្ថុ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាន គណៈគ្រប់គ្រងសាលា ដើម្បីសិក្សាអំពីស្ថានភាព និង កំណត់តម្រូវការជាក់លាក់ យ៉ាងយឺតបំផុតត្រឹមសប្តាហ៍ទី៣ ខែ កញ្ញា ឆ្នាំ២០២៥។

**សកម្មភាពទី១.១៖** បែកចែកតួនាទីនៃសមាជិកគម្រោងទៅលើការធ្វើផែនការហិរញ្ញវត្ថុ និងទាក់ទងអាជ្ញាធរមូលដ្ឋានព្រមទាំងនាយកសាលារយៈពេលមួយថ្ងៃក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៥។

***ហានិភ័យទី១.១.១៖*** ភាពមិនច្បាស់លាស់នៅក្នុងការបែកចែកភារកិច្ច តួនាទី ទំនួលខុសត្រូវសម្រាប់សមាជិកម្នាក់ៗដែលនាំឲ្យមានភាពយឺតយ៉ាវ។

**សកម្មភាពទី១.២៖** ចុះដល់ទីតាំងដើម្បីជួបពិភាក្សាជាមួយគណៈគ្រប់គ្រងសាលាដើម្បីដឹងពីតម្រូវការធនធានបណ្ណាល័យជាក់ស្តែង រយៈពេលពីរថ្ងៃ ក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៥។

***ហានិភ័យទី១.២.១៖*** តម្រូវការធនធានជាក់ស្តែងពីគណៈគ្រប់គ្រងសាលា មានកម្រិតខ្ពស់ជាងសមត្ថភាពនៃការផ្តល់ជូន ពីគម្រោង។

**សកម្មភាពទី១.៣៖** ការរៃអង្គាសប្រមូលថវិកាដើម្បីយកមកបែងចែក តាមកញ្ចប់ចំណាយនីមួយៗ និងធ្វើរបាយការណ៍បូកសរុបចំណូលចំណាយ ដោយយ៉ាងយូរបំផុតត្រឹមសប្តាហ៍ទី៣ នៃខែកញ្ញា ឆ្នាំ ២០២៥។

***ហានិភ័យទី១.៣.១៖*** ការរៀបចំមិនគ្រប់គ្រាន់នៃធនធានអំណោយ រយៈពេលនៃការអនុវត្តមិនគ្រប់គ្រាន់ និង ការខូចខាតនូវធនធានអំណោយ។

**គោលដៅទី២៖ ដំណើរដល់ទីតាំង ដើម្បីរៀបចំប្រគល់ធនធានបណ្ណាល័យ ដល់គណៈគ្រប់គ្រងសាលានិងចូលរួមថតរូបទុកជាអនុស្សាវរីយ៍ជាមួយលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស យ៉ាងយឺតបំផុតត្រឹមសប្តាហ៍ទី៤ ខែ កញ្ញា ឆ្នាំ២០២៥។**

**សកម្មភាពទី២.១៖** សិក្សាពីតម្លៃថ្លៃដើមនៃធនធានបណ្ណាល័យតាមការកំណត់ជាមួយបណ្តាអ្នកផ្គត់ផ្គង់ដោយមិនលើសពីសប្តាហ៍ទី៣ ខែ កញ្ញា ឆ្នាំ២០២៥។

***ហានិភ័យទី២.១.១៖*** ការឡើងថ្លៃនៃធនធានបណ្ណាល័យដោយតម្លៃលើសពីការរំពឹងទុក និងឥវ៉ាន់ខ្លះមិនល្អធ្វើអោយមានបញ្ហាពេលវេចខ្ចប់។

**សកម្មភាពទី២.២៖** ដឹកជញ្ជូនសម្ភារៈទៅកាន់ទីតាំងនិងរៀបចំតម្លើង ក្នុងសប្តាហ៍ទី៤ ខែកញ្ញា ឆ្នាំ ២០២៥។សំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស រួចធ្វើការប្រគល់ធនធានបណ្ណាល័យជូនដល់គណៈគ្រប់គ្រងសាលា ក្នុងសប្តាហ៍ទី៤ ខែ កញ្ញា ឆ្នាំ២០២៥។

***ហានិភ័យទី២.២.១៖*** ការរំខានដល់ការធ្វើដំណើរដែលមិនបានរំពឹងទុក ដោយកត្តាមួយចំនួនដូចជាការកកស្ទះចរាចរ មានភ្លៀងធ្លាក់ធ្វើដាច់ផ្លូវធ្វើដំណើរ។

**សកម្មភាពទី២.៣៖** មានការលេងល្បែងកំសាន្តជាមួយសិស្សានុសិស្ស ការថតរូបទុកជាអនុស្សាវរីយ៍ និងថ្លែងអំណរគុណដល់សប្បុរសជន ក្នុងសប្តាហ៍ទី៤ ខែ កញ្ញា ឆ្នាំ២០២៥។

***ហានិភ័យទី២.៣.១៖*** សិស្សានុសិស្សមិនចូលរួមលេងល្បែងកំសាន្តតាមការដែលបានគ្រោងទុក និងឧបករណ៍ថតរូបមានបញ្ហាបច្ចេកទេស ឬ ការផ្ទុកទន្នន័យនៃឧបករណ៍ពេញ។

**គោលដៅទី៣៖បូកសរុបលទ្ធផលការងារ និង ចំណាយសម្រាប់ការអនុវត្តគម្រោងទាំងមូល និងសរសេរជារបាយការណ៍ សម្រាប់ប្រគល់ជូនភាគីដែលពាក់ព័ន្ធយ៉ាងយូរបំផុតត្រឹមសប្តាហ៍ទី៣ ខែ តុលា ឆ្នាំ ២០២៥។**

**សកម្មភាពទី៣.១៖** ក្រុមការងារបានធ្វើការបូកសរុបថវិកា ដែលបានចំណាយសម្រាប់គម្រោងទាំងមូល នៅត្រឹមសប្តាហ៍ទី២ ខែ តុលា ឆ្នាំ ២០២៥។

***ហានិភ័យទី៣.១.១៖*** កំហុសអំឡុងពេល គណនាថវិកា ឬ ការបាត់វិក័យប័ត្រទំនិញដែលបានបញ្ជាទិញ។

**សកម្មភាពទី៣.២៖** ក្រុមការងារបូកសរុបនូវលទ្ធផលនានានៃគម្រោងនៅនៅត្រឹមសប្តាហ៍ទី២ ខែ តុលា ឆ្នាំ ២០២៥។

***ហានិភ័យទី៣.២.១៖*** ការបាត់បង់កម្រងរូបថតនិងវិដេអូដែលមិនបានកត់ត្រាទុកក្នុងអង់ផ្ទុកទិន្នន័យនៃឧបករណ៍ថតរូប។

**សកម្មភាពទី៣.៣៖** ក្រុមការងារសរសេរបញ្ចប់របាយការណ៍ជូនសាធារណជនឬអ្នកដែលបានចូលរួមដោយខ្លឹមសារស្តីអំពីការស្រាវជ្រាវ ការអនុវត្ត និងលទ្ធផលនានានៃគម្រោង ដែលមានការរួមបញ្ចូលទិន្នន័យវាយតម្លៃ ការប្រៀបធៀប និងសំណួរស្រាវជ្រាវ។ការបញ្ចប់នៃសកម្មភាពនេះនឹងប្រព្រឹត្តទៅនៅសប្តាហ៍ទី៣ ខែតុលា ឆ្នាំ ២០២៥។

***ហានិភ័យទី៣.៣.១៖*** កង្វះខាតនៃការកែសម្រួលដែលប៉ះពាល់ដល់គុណភាពរបាយការណ៍ និងមិនបានប្រគល់របាយការណ៍ទៅកាន់ភាគីដែលពាក់ព័ន្ធ។

## ជំពូកទី២៖ ដំណើរការអនុវត្តគម្រោង និង ការជ្រើសរើសធនធានមនុស្ស

### ២.រចនាសម្ព័ន្ធ និង អង្គភាពលេខ

ការបែងចែកធនធានមនុស្ស នៅក្នុងគម្រោងស្តីពី៖ កម្មវិធីឧបត្ថម្ភធនធានបណ្ណាល័យសម្រាប់អនុវិទ្យាល័យ ត្រកៀត ដែលស្ថិតនៅ ភូមិត្រកៀត ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវមានសមាសភាពដូចខាងក្រោម៖

**ក. ប្រធានគម្រោង៖** មានកាតព្វកិច្ច និងទំនួលខុសត្រូវដូចជា៖

- គ្រប់គ្រង ដឹកនាំ និង សម្របសម្រួល ក្រុមការងារ និងភាគីដែលពាក់ព័ន្ធទាំងមូល។
- អនុម័តផែនការនានា( ហរិញ្ញវត្ថុ និង ផែនការអនុវត្ត) និងត្រួតពិនិត្យ វាយតម្លៃលទ្ធផលគម្រោង។

**ខ. ផ្នែករៀបចំផែនការ៖** មានកាតព្វកិច្ច និង ទំនួលខុសត្រូវដូចជា៖

- បែងចែកភារកិច្ចការងារ និងរៀបចំកាលវិភាគការងារសម្រាប់ក្រុមការងារ។
- តាមដាន និង ធ្វើរបាយការណ៍អំពីវឌ្ឍនភាពនានៃគម្រោងទៅកាន់ប្រធានគម្រោង។

**គ. ផ្នែកហិរញ្ញវត្ថុ៖** មានកាតព្វកិច្ច និង ទំនួលខុសត្រូវដូចជា៖

- រៀបចំ និងតាមដានផែនការថវិកា និងការចំណាយផ្សេងៗរបស់គម្រោង។
- ត្រួតពិនិត្យ និងរៀបចំរបាយការណ៍ថវិកា និងចំណាយជាប្រចាំទៅកាន់ប្រធានគម្រោង។

**ឃ. ផ្នែកទំនាក់ទំនង និងសហប្រតិបត្តិការ៖** មានកាតព្វកិច្ច និងទំនួលខុសត្រូវដូចជា៖

- ជាភ្នាក់ងារទំនាក់ទំនងទៅកាន់អាជ្ញាធរមូលដ្ឋានតំណាងសាលារៀន។
- ទាក់ទង និង ផ្សព្វផ្សាយ ព័ត៌មានតាមបណ្ដាញសង្គមផ្សេងៗ និងធ្វើការប្រមូលថវិកាឧបត្ថម្ភ។

ក្នុងការរៀបចំគម្រោង "**គម្រោងផ្ដល់ធនធានបណ្ណាល័យនៅអនុវិទ្យាល័យត្រកៀត ស្រុកបាទី ខេត្តតាកែវ**" មានក្រុមការងារស្ម័គ្រចិត្តចំនួន ៧រូប និងត្រូវ បែងចែកតួនាទី និងភារកិច្ចដូចខាងក្រោម៖

**រចនាសម្ព័ន្ធ**

| ល.រ | តួនាទី | ភារកិច្ច |
|---|---|---|
| ១ | ប្រធានគម្រោង | • រៀបចំនីតិវិធីបង្កើតក្រុមការងារ<br>• គ្រប់គ្រងដំណើរការគម្រោង<br>• តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តគម្រោង ទាំងមូល |
| ២&៣ | មន្ត្រីហិរញ្ញវត្ថុ | • ត្រួតពិនិត្យឯកសារហិរញ្ញវត្ថុ<br>• ចាត់ចែងថវិកាសម្រាប់សកម្មភាពផ្សព្វផ្សាយ<br>• ធ្វើរបាយការណ៍ចំណូល-ចំណាយ |
| ៤ | មន្ត្រីរដ្ឋបាល | • រៀបចំលិខិតស្នាមផ្សេងៗ<br>• រក្សាទុកឯកសារ ទិន្នន័យ និងរបាយការណ៍<br>• ធ្វើកំណត់ហេតុកិច្ចប្រជុំ |
| ៥ | មន្ត្រីផ្សព្វផ្សាយ | • រៀបចំសម្របសម្រួលសម្រាប់ការផ្សព្វផ្សាយតាមបណ្ដាញសង្គម និងការអែអង្គាសផ្ទាល់ |
| ៦ | មន្ត្រីទំនាក់ទំនង | • ទំនាក់ទងទៅអាជ្ញាធរ និងគណៈគ្រប់គ្រងសាលា ចាត់ចែងមធ្យោបាយធ្វើដំណើរ និងការដឹកជញ្ជូន |
| ៧ | ពិធីការ | • រៀបចំសុន្ទរកថា<br>• ចាសម្របសម្រួលកម្មវិធី និងល្បែងកំសាន្ត |

## អង្គការលេខ




## ២.២. ការប្រើប្រាស់ធនធានគម្រោង

| ល.រ | បរិយាយ | ចំនួន | ឯកតា | តម្លៃឯកតា | តម្លៃសរុប | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១ | ការចុះសិក្សាផ្ទាល់ដល់ទីតាំង | ២ | នាក់ | ២៥ដុល្លារ | ៥០ដុល្លារ | |
| ២ | សៀវភៅរឿងនិទាន និង ចំណេះដឹងទូទៅ | ២០០ | ក្បាល | ២.៥ដុល្លារ | ៥០០ដុល្លារ | |
| ៣ | ទូរដាក់សៀវភៅ | ៣ | ទូរ | ៥០ដុល្លារ | ១៥០ដុល្លារ | |
| ៤ | សម្ភារកម្សាន្តបង្កើនសមត្ថភាព ខួរក្បាល | ៤ | ឈុត | ២៥ដុល្លារ | ១០០ដុល្លារ | |
| ៥ | អាហារសម្រន់ ទឹកសុទ្ធ សម្រាប់កម្មវិធី | ១០០ | នាក់ | ១.២ដុល្លារ | ១២០ដុល្លារ | |
| ៦ | មធ្យោបាយដឹកជញ្ជូនសម្ភារ និងធ្វើដំណើរ | ៣ | គ្រឿង | ៦០ ដុល្លារ | ១៨០ដុល្លារ | |
| | | | | សរុប | ១ ១០០ដុល្លារ | |

## ២.៣. ការតាមដានត្រួតពិនិត្យគម្រោង ការវាយតម្លៃគម្រោង និងការតាម ដានបន្ត

### ២.៣.១. ការតាមដានត្រួតពិនិត្យគម្រោង

ក្នុងពេលអនុវត្តគម្រោង ក្រុមការងារស្ម័គ្រចិត្ត ធ្វើការតាមដានត្រួតពិនិត្យលើដំណើរការប្រព្រឹត្តទៅរបស់គម្រោង ថាតើការអនុវត្តគម្រោងស្របតាមកាលវិភាគ និងទាន់ពេលវេលាដែលបានគ្រោង

ទុក ការចាត់ចែងការងារក្នុងគោលដៅ និងសកម្មភាពនីមួយៗមានប្រសិទ្ធភាព និងដំណើរការទៅបាន ដោយរលូនតាំងពីពេលចាប់ផ្តើមរហូតដល់បញ្ចប់គម្រោង។

### ២.៣.២. ការវាយតម្លៃគម្រោង

| ID | Task Name | Duration | Start | Finish |
|---|---|---|---|---|
| 1 | គម្រោងផ្តល់ធនធានបណ្ណាល័យនៅអនុវិទ្យាល័យក្រគៀកដែលស្ថិតនៅ ភូមិក្រគៀក ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ | 30 days | Mon 9/15/25 | Fri 10/24/25 |
| 2 | គោលដៅទី១៖ បង្កើតក្រុមការងារ ពិភាក្សាពីតម្រូវការធនធានបណ្ណាល័យសកម្មភាពគម្រោង ផែនការហិរញ្ញវត្ថុ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាន គណៈគ្រប់គ្រងសាលា ដើម្បីសិក្សាអំពីស្ថានភាព និង កំណត់តម្រូវការជាក់លាក់ យ៉ាងយឺតបំផុតត្រឹមសប្តាហ៍ទី៣ ខែ កញ្ញា ឆ្នាំ២ | 6 days | Mon 9/15/25 | Sun 9/21/25 |
| 3 | គោលដៅទី២៖ ដំណើរដល់ទីតាំង ដើម្បីរៀបចំប្រគល់ធនធានបណ្ណាល័យ ដល់គណៈគ្រប់គ្រងសាលានិងចូលរួមថតរូបទុកជាអនុស្សាវរីយ៍ជាមួយលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សយ៉ាង យឺតបំផុតត្រឹមសប្តាហ៍ទី៤ ខែ កញ្ញា ឆ្នាំ២០២៥។ | 17 days | Mon 9/22/25 | Tue 10/14/25 |
| 4 | គោលដៅទី៣៖បូកសរុបលទ្ធផលការងារ និងចំណាយសម្រាប់ការអនុវត្តគម្រោងទាំងមូល និងសរសេរជារបាយការណ៍ សម្រាប់ប្រគល់ជូនភាគីដែលពាក់ព័ន្ធយ៉ាងយូរបំផុតត្រឹមសប្តាហ៍ទី៣ ខែ តុលា ឆ្នាំ ២០២៥។ | 9 days | Tue 10/14/25 | Fri 10/24/25 |

9 14

Project: Project1
Date: Thu 9/4/25

| | | |
|---|---|---|
| Task | Inactive Summary | External Tasks |
| Split | Manual Task | External Milestone |
| Milestone | Duration-only | Deadline |
| Summary | Manual Summary Rollup | Progress |
| Project Summary | Manual Summary | Manual Progress |
| Inactive Task | Start-only | |
| Inactive Milestone | Finish-only | |

Page 1




សមាជិកក្រុមការងារធ្វើការវាយតម្លៃ ដោយប្រមូលព័ត៌មានដែលពាក់ព័ន្ធ តាមដានការអនុវត្តការងារដល់ទីតាំងផ្ទាល់។ សមាជិកក្រុមធ្វើទិន្នន័យដែលទទួលបានពីការត្រួតពិនិត្យផ្ទាល់យកមកវិភាគ និងធ្វើរបាយការណ៍ ព្រមទាំងផ្តល់អនុសាសន៍ជូនប្រធានគម្រោង។

### ២.៣.៣. ការតាមដានបន្ត

ក្រោយពីគម្រោងនេះបានបញ្ចប់រួចរាល់ ប្រធានគម្រោងត្រូវដឹកនាំសមាជិកគម្រោងចុះតាម ដានពីការប្រើប្រាស់ និងថែរក្សាធនបណ្ណាល័យរបស់លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស ថាមានការបាត់បង់ រឺខូចខាត និងបានទទួលអត្ថប្រយោជន៍ពីការអានសៀវភៅរបស់គម្រោងបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក។

## ២.៤. ការបញ្ចប់គម្រោង និងការផ្ទេរនិរន្តរភាពរបស់គម្រោង

### ២.៤.១. ការបញ្ចប់គម្រោង

គម្រោងនេះត្រូវបានគ្រោងទុកដែលមានរយៈពេល ១ខែ ចាប់ពីសប្តាហ៍ទី៣ ខែកញ្ញា ដល់សប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២៥។ បន្ទាប់ពីបញ្ចប់គម្រោងនេះ តាមរយៈការទទួលបានធនធានបណ្ណាល័យសិស្សានុសិស្សពិតជាទទួលបានចំណេះដឹងពីការអានសៀវភៅ ដែលធ្វើឱ្យសិស្សានុសិស្សមានទម្លាប់ក្នុងការអានសៀវភៅ និង យល់ពីអត្ថប្រយោជន៍ក្នុងការអានសៀវភៅ។

### ២.៤.២. ការផ្ទេរនិរន្តភាពរបស់គម្រោង

ក្រោយពីគម្រោងបានបញ្ចប់ ដើម្បីបន្តនិរន្តភាពនៃការប្រើប្រាស់ធនធានបណ្ណាល័យ ក្រុមការងារ សម្រេចប្រគល់ការគ្រប់គ្រងបន្តជូនដល់គណៈគ្រប់គ្រងសាលាដើម្បីប្រើប្រាស់ ថែរក្សា ឱ្យបានត្រឹមត្រូវជៀសវាងមានការខូចខាត ឬ បាត់បង់ដោយប្រការណាមួយ ដើម្បីផ្តល់ជាប្រយោជន៍ជូនដល់សិស្សានុសិស្សគ្រប់ជំនាន់ពីគម្រោងនេះ។

## ជំពូកទី៣ ៖ ការវិភាគ SWOT លើដំណើរការអនុវត្តគម្រោង

គម្រោង "**ផ្តល់ធនធានបណ្ណាល័យនៅអនុវិទ្យាល័យត្រកៀត ស្រុកបាទី ខេត្តតាកែវ**" គឺជាកម្មវិធីសប្បុរសធម៌ ដែលមាន ចូលរួមមូលនិធិសប្បុរសធម៌ សំណាក់និស្សិតថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ ឯកទេស គ្រប់គ្រង នៃ ជំនាន់ទី២១ ជំហាន២ (MBM21-2A) នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច និង សប្បុរសជន ដទៃដែលមានគោលបំណង ដើម្បីចូលរួមជួយសម្រួលដល់ជីវភាព និង លើកទឹកចិត្តសិស្សានុសិស្សនៅក្នុង ឃុំ ចំប៉ី ស្រុក បាទី ខេត្តតាកែវតាមរយៈការផ្តល់អំណោយសប្បុរសធម៌ជាសម្ភារៈបណ្ណាល័យ ដែលចាំបាច់ និងថវិកាសម្រាប់ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀន។ ជាមួយគ្នានេះដែរ ក្នុងការអភិវឌ្ឍន៍គម្រោង ការវិភាគ SWOT លើដំណើរការអនុវត្តគម្រោងរួមមានដូចខាងក្រោម៖

### ៣.១. ចំណុចខ្លាំង

- **ការបែងចែកក្រុមការងារគ្រប់គ្រងអនុវត្ត៖** ការបង្កើតក្រុមការងារ ជួយឲ្យមានការបែងចែកភារកិច្ចច្បាស់លាស់ ហើយជួយឲ្យការងារមានភាពងាយស្រួលនិងរលូន។
- **កាលវិភាគអនុវត្តគម្រោងមានរចនាសម្ព័ន្ធច្បាស់លាស់៖** គម្រោងមានការរៀបចំល្អជាមួយនឹងកាលបរិច្ឆេទកំណត់សម្រាប់សកម្មភាពនីមួយៗ ដែលវាជួយឲ្យក្រុមការងារអាចគ្រប់គ្រងពេលវេលាឲ្យបានមានប្រសិទ្ធភាព និងគ្រប់គ្រងការអនុវត្តស្របតាមផែនការ។
- **ការប្រើប្រាស់ឯកសារ និងឧបករណ៍ជំនួយ៖** ប្រើប្រាស់ឯកសារយោង (លិខិតស្នើសុំ លិខិតអនុញ្ញាតរបាយការណ៍ពាក់ព័ន្ធ រូបថត និង វិដេអូនៃសកម្មភាពគម្រោង) ដើម្បីបញ្ជាក់ថាសកម្មភាពបានអនុវត្តជាក់ស្តែង និងជួយបង្ហាញពីភាពមានទំនួលខុសត្រូវនៃគម្រោងដើម្បីទុកជូនភាគីដែលពាក់ព័ន្ធ ។
- **ប្រព័ន្ធប្រមូលមតិយោបល់៖** ការប្រមូលមតិ យោបល់ពីសាលា និងអ្នកចូលរួមជួយវាយតម្លៃគម្រោងទាំងមូលបានកាន់តែទូលំទូលាយ ដែលការវាយតម្លៃនេះ ជួយបង្កើននូវការចូលរួម និងបន្តការអភិវឌ្ឍគម្រោងនាពេលក្រោយទៀតៗ។

• **បេសកកម្មសប្បុរសធម៌ដ៏មានអត្ថន័យ៖** គម្រោងផ្តោតលើការជួយសម្រួលដល់សិស្សានុ-សិស្សអោយមានធនធានសម្រាប់ស្រាវជ្រាវគ្រប់គ្រាន់ វាថែមទាំងជួយទាក់ទាញចិត្តសប្បុរសធម៌ឲ្យមានការចូលរួមកាន់តែច្រើន និងជំរុញឲ្យអ្នកស្ម័គ្រចិត្ត និងអ្នកឧបត្ថម្ភចូលរួមយ៉ាងសកម្មផងដែរ។

**៣.២. ចំណុចខ្សោយ**

• **មូលនិធីសប្បុរសនៅមានកម្រិត៖** ដោយសារការប្រមូលមូលនិធិមានរយៈពេលខ្លី ដែលតម្រូវឱ្យកញ្ចប់អំណោយសប្បុរស និង ថវិកាឧបត្ថម្ភ នៅមានកម្រិតតិចតួច បើធៀបទៅនឹងកង្វះខាតជាក់ស្តែងដែលគម្រោងបានស្វែងយល់។

• **ការត្រួតពិនិត្យនៅមានកម្រិត៖** ដោយសារចំនួនសមាជិកគម្រោងមានកម្រិតតិចតួចបើធៀបទៅនឹងចំនួនច្រើននៃអ្នកចូលរួម រួមបញ្ចូលនិស្សិតមកពីក្រុងភ្នំពេញ និង អ្នកចូលរួមផ្ទាល់នៅក្នុងតំបន់ បានធ្វើឱ្យមានចន្លោះខ្វះខាតមួយចំនួន ក្នុងការត្រួតពិនិត្យគុណភាពការងារ។

• **ហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់គោលដៅ និងអាកាសធាតុ៖** ស្ថានភាពផ្លូវធ្វើដំណើរអាចមិនសូវល្អ ឬស្ថានភាពអាកាសធាតុអាចបណ្តាលឲ្យពន្យារពេលការដឹកជញ្ជូនសម្ភារៈ និងការទៅដល់គោលដៅតាមពេលវេលាកំណត់។

**៣.៣. ឱកាស**

• **លទ្ធភាពទទួលការអប់រំ៖** ផ្តល់លទ្ធភាពសម្រាប់សិស្សានុសិស្ស ក្នុងការស្រាវជ្រាវជាបន្តបន្ទាប់បានងាយស្រួល។

• **ពង្រឹងគុណភាពអប់រំ៖**ផ្តល់ជាទុនរួមចំណែកក្នុងការពង្រឹងគុណភាពអប់រំសម្រាប់សិស្សានុសិស្សនៅតំបន់នោះ។

• **ពង្រីកទំនាក់ទំនង៖**បង្កើនទំនាក់ទំនងជិតស្និតរវាងក្រុមការងារគម្រោង គណៈគ្រប់គ្រងសាលារៀនសិស្សានុសិស្ស និង អាជ្ញាធរក្នុងតំបន់។

• **យុវជន និង សកម្មភាពសង្គម៖** ផ្តល់ឱកាស និង លើកទឹកចិត្តដល់ក្រុមយុវជន ឱ្យចូលរួមសកម្មភាពសង្គម។

• **ការផ្សព្វផ្សាយ៖** ជាឱកាសក្នុងការផ្សព្វផ្សាយពីភាពវិជ្ជមានលើការងារសង្គម ដែលអាចជួយទាក់ទាញ អ្នកបរិច្ចាកកាន់តែច្រើននាពេលអនាគត។

**៣.៤. ការគំរាមកំហែង**

• **លក្ខខណ្ឌរៀបចំរចនាសម្ព័ន្ធក្រុម៖** ការបែងចែកភារកិច្ច តួនាទី ទំនួលខុសត្រូវ សម្រាប់សមាជិក ម្នាក់ៗដែលនាំឱ្យមានភាពយឺតយ៉ាវក្នុងការអនុវត្តគម្រោង។

• **លក្ខខណ្ឌអាកាសធាតុ៖**នៅក្នុងរដូវវស្សាមិនសូវអំណោយផលដល់ការអនុវត្តគម្រោងនៅនឹងទីតាំងដែលបានកំណត់។

- **លក្ខខណ្ឌសុខភាព និង សុវត្ថិភាព៖** ក្នុងការធ្វើដំណើរ និង ស្នាក់នៅទីតាំង ដែលបានកំណត់របស់ក្រុមការងារគម្រោង មានកម្រិតគ្រោះថ្នាក់ ដោយសារវាជាតំបន់ព្រៃភ្នំ។
- **លក្ខខណ្ឌវប្បធម៌ និង ការរស់នៅ៖** វាអាចមានភាពខុសគ្នារវាងក្រុមការងារ និង ប្រជាជនក្នុងស្រុកស្ទួល ដែលនាំឱ្យមានការយល់ច្រលំផ្សេងៗ។
- **លក្ខខណ្ឌទំនុកចិត្ត៖** វាអាចមានការមិនទុកចិត្តពីសំណាក់អ្នកបរិច្ចាក លើការប្រើប្រាស់ថវិកាដោយមិនមានតម្លាភាព។

## សេចក្តីសន្និដ្ឋាន

ក្រោយពេលអនុវត្តគម្រោងសប្បុរសធម៌នេះរួចរាល់ គម្រោងបានបង្ហាញពីជោគជ័យយ៉ាងច្បាស់លាស់ទាំងនៅក្នុងការធ្វើផែនការ ការអនុវត្ត ការតាមដាន និង ការវាយតម្លៃគម្រោង។ម្យ៉ាងទៀត ការចូលរួមយ៉ាងសកម្មពីសមាជិកគម្រោងទាំងអស់ និងការគាំទ្រពីសហគមន៍ បានជះឥទ្ធិពលវិជ្ជមានយ៉ាងខ្លាំងទៅលើសិស្សានុសិស្ស នៅសាលាបឋមសិក្សាដែលជាគោលដៅនៃគម្រោង។ការបង្កើតអោយមានទំនាក់ទំនងសង្គមរវាងសិស្ស និស្សិតជាមួយប្រជាជន និង សិស្សានុសិស្សនៅតាមសហគមន៍។បើទោះជាមានឧបសគ្គ និងហានិភ័យខ្លះៗក្នុងការអនុវត្តជាពិសេសទាក់ទងនឹងការដឹកជញ្ជូន សភាពអាកាសធាតុ ឬការលំបាកក្នុងការរកឧបត្ថម្ភ ក៏ដោយគម្រោងនេះត្រូវបានអនុវត្តដោយជោគជ័យ និងគ្មានបញ្ហាធ្ងន់ធ្ងរណាមួយ។

តាមរយៈសកម្មភាពស្ម័គ្រចិត្តរបស់និស្សិតអាចជាជំនួយដ៏សំខាន់ដែលបង្ហាញអាចថាស្ថាប័នអប់រំក៏ចំណែកមួយដែលធ្វើអោយសង្គមមានរីកចម្រើន។ទាំងអស់នេះជាមេរៀនដ៏មានន័យសម្រាប់និស្សិត និងជាគំរូល្អសម្រាប់គម្រោងសប្បុរសធម៌នាពេលអនាគត។